ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

**ផ្ញើពី/From:** ឯ.ឧ. គង់ ស្រ៊ឹម ប្រធាននៃគណៈកម្មាធិការរដ្ឋបាលតុលាការនៃ អ.វ.ត.ក.
**H.E. Kong Srim, President of the Judicial Administrative Committee (JAC)**

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៩
Date: 17 December 2019

**ផ្ញើជូន/To:** គ្រប់ភាគីនៃសំណុំរឿង ០០២
**All parties, Case 002**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Dec-2019, 12:15
CMS/CFO: Sann Rada

**ចម្លងជូន/ CC:** ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល
**Judges of the Supreme Court Chamber**
សមាជិកនៃគណៈកម្មាធិការរដ្ឋបាលតុលាការ និងក្រុមប្រឹក្សាជំនុំជម្រះ
**Judicial Administration Committee, Special Panel**
ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ហួត វុទ្ធី ចៅក្រម ន័យ ថុល ចៅក្រម ស៊ិន រិទ្ធ
**Judge Olivier Beauvallet, Judge Kang Jin Baik , Judge Steven Bwana**

**កម្មវត្ថុ/ Subject:** ការជ្រើសតាំងក្រុមប្រឹក្សាជំនុំជម្រះលើសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម
**Appointment of replacement judges to hear KHIEU Samphân's disqualification motion**

នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ គណៈកម្មាធិការរដ្ឋបាលតុលាការ (JAC) បានជូនដំណឹងអំពីសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសដើម្បីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដិតចិត្តចៅក្រមដោយអនុលោមតាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង។ នៅក្នុងនោះ JAC បានសម្រេចជាឯកច្ឆន្ទជ្រើសរើសលោកចៅក្រម ប្រាក់ គឹមសាន ជាប្រធាន ចៅក្រម ហួត វុទ្ធី ចៅក្រម ន័យ ថុល ចៅក្រម ស៊ិន រិទ្ធ ចៅក្រម Kang Jin Baik ចៅក្រម Maureen Harding Clark និងចៅក្រម Olivier Beauvallet។

នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៩ លោកស្រីចៅក្រម Maureen Harding Clark បានជូនដំណឹងដល់ប្រធាននៃគណៈកម្មាធិការរដ្ឋបាលតុលាការថា លោកស្រីបានសម្រេចដកខ្លួនចេញពីក្រុមជំនុំជម្រះពិសេសនេះ

ដោយសារលោកស្រីធ្លាប់បានចូលរួមក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលរងការជំទាស់ដោយមេធាវីការពារក្តីរបស់ ខៀវ សំផន។

ដូច្នេះ JAC តម្រូវកោះប្រជុំសាឡើងវិញ និងបានសម្រេចជាឯកច្ឆន្ទដោយជ្រើសរើសចៅក្រម Steven Bwana ជំនួសលោកស្រីចៅក្រម Clark ក្នុងក្រុមប្រឹក្សាជំនុំជម្រះពិសេសនេះ។

អាស្រ័យហេតុនេះ ខ្ញុំសូមជម្រាបជូនជាដំណឹងថា ក្រុមប្រឹក្សាថ្មីជំនុំជម្រះសំណើសុំប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ មានសមាសភាពដូចខាងក្រោម៖

១. ចៅក្រម ប្រាក់ គឹមសាន ប្រធាន

២. ចៅក្រម ហួត វុទ្ធី

៣. ចៅក្រម ន័យ ថុល

៤. ចៅក្រម ស៊ិន រិទ្ធ

៥. ចៅក្រម Kang Jin Baik

៦. ចៅក្រម Olivier Beauvallet

៧. ចៅក្រម Steven Bwana

On 4 December 2019, the Judicial Administration Committee (JAC) notified the constitution of a special panel pursuant to Internal Rule 34(6) to hear KHIEU Samphân's disqualification motion. The JAC unanimously selected Judges Prak Kimsan (Presiding), Huot Vuthy, Ney Thol, Sin Rith, Kang Jin Baik, Maureen Harding Clark and Olivier Beauvallet to sit on the panel.

On 13 December 2019, Judge Clark notified the President of the JAC that she would recuse herself from sitting on the special panel, having formed part of the Supreme Court Chamber bench which rendered a decision which is now impugned by the Khieu Samphan defence.

The JAC accordingly reconvened and unanimously selected Judge Steven Bwana to replace Judge Clark on the special panel.

I hereby notify you that the following judges constitute the bench for the hearing of the disqualification motion against the six Supreme Court Chamber judges in case 002/02:

1. Judge Prak Kimsan, Presiding
2. Judge Huot Vuthy
3. Judge Ney Thol
4. Judge Sin Rith
5. Judge Kang Jin Baik
6. Judge Olivier Beauvallet
7. Judge Steven Bwana